# ព្រលឹងខ្ញុំត្រេកអរចំពោះការណ៍ទាំងឡាយនៃព្រះអម្ចាស់

ស៊ូសាន ដុបលយូ ថែនណឺ
ត្រូវបានដោះលែងពីការបំរើជាប្រធានយុវនារីទូទៅក្នុងពេលថ្មីៗនេះ

*ការត្រេកអរនៅក្នុងព្រះអម្ចាស់... នឹង "លើក" ដួងចិត្តរបស់យើងឡើង ហើយផ្តល់ឱ្យយើងនូវមូលហេតុដើម្បី "រីករាយ"*

នៅក្នុងព្រះគម្ពីរមរមន នីហ្វៃបាននិយាយជារឿយៗអំពីការត្រេកអរ ។ គាត់ត្រេកអរនៅក្នុង "ការណ៍ទាំងឡាយនៃព្រះអម្ចាស់" នៅក្នុងព្រះគម្ពីរ និងនៅក្នុង "ផែនការដ៏ធំ ហើយអស់កល្បជានិច្ច" របស់ព្រះអម្ចាស់ ។ (សូមមើលនីហ្វៃទី 2 4:15--16, 11:2--8) ។ ដោយកត់ចំណាំឃើញថា ជារឿយៗនីហ្វៃចងចាំអំពីប្រភពនៃការត្រេកអររបស់គាត់នៅក្នុងការរងទុក្ខ ការបំរើដើម្បីលើកដំកើង និងផ្តោតវិញ្ញាណរបស់លោកទៅលើពរជ័យដ៏នៅអស់កល្បជានិច្ច ។

យើងគួរតែត្រេកអរផងដែរនៅក្នុងការណ៍ទាំងឡាយនៃព្រះអម្ចាស់ ព្រោះវានឹង "លើក" ដួងចិត្តរបស់យើងឡើង ហើយផ្តល់ឱ្យយើងនូវមូលហេតុដើម្បី "រីករាយ" (នីហ្វៃទី 2 11:8) ។ ខ្ញុំសូមប្រាប់អំពីការណ៍មួយចំនួនដែលខ្ញុំត្រេកអរ ។

ខ្ញុំត្រេកអរនៅក្នុងព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ ។ ដូចជានីហ្វៃ "សរសើរដំកើងនៅក្នុងព្រះយេស៊ូវរបស់ខ្ញុំ" (នីហ្វៃទី 2 33:6 ) នៅក្នុងការបំរើ និងតួនាទីសង្គ្រោះនៅលើផែនដីរបស់ទ្រង់ ។ ទ្រង់ផ្តល់ពន្លឺ និងក្តីសង្ឃឹម ហើយបានផ្តល់នូវព្រះវិញ្ញាណបរិសុទ្ធដល់យើង ដើម្បីធ្វើជាការដឹកនាំ និងការលួងលោមបន្ថែមនៅតាមផ្លូវជីវិតដែលយើងគួរតែដើរទៅ ។ មានតែតាមរយៈទ្រង់ប៉ុណ្ណោះ ដែលយើងអាចត្រឡប់ទៅកាន់ព្រះវរបិតារបស់យើងវិញ ។ "សេចក្តីសង្គ្រោះមកឱ្យកូនចៅមនុស្ស មានតែមធ្យោបាយមួយប៉ុណ្ណោះ គឺដោយតាមរយៈព្រះនាមនៃព្រះគ្រីស្ទ ជាព្រះអម្ចាស់ដ៏មានគ្រប់ព្រះចេស្តា" (ម៉ូសាយ 3:17) ។

ខ្ញុំត្រេកអរនៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ដែលសង់នៅលើគ្រឹះនៃពួកសាវក និងពួកព្យាការី ដែលខ្ញុំបានប្រទានពរនូវឱកាសដើម្បីបំរើជាមួយពួកលោក ។ ខ្ញុំសូមធ្វើទីបន្ទាល់ថាប្រធាន ថូម៉ាស អេស ម៉នសុន គឺជាព្យាការីរបស់ព្រះអម្ចាស់នៅលើផែនដីសព្វថ្ងៃនេះ ។ ខ្ញុំត្រេកអរដែលលោកគឺជាអ្នកបំរើដូចជាព្រះគ្រីស្ទដ៏ពិតចំពោះមនុស្សម្នាក់ៗ ឈោងទៅរកដោយភាពកក់ក្តៅ និងក្តីស្រឡាញ់ដល់បុគ្គលម្នាក់ៗ ។

ខ្ញុំត្រេកអរនៅក្នុងកូនសោបព្វជិតភាព និងព្រះវិហារបរិសុទ្ធដែលមាននៅលើផែនដី ដែលធ្វើឱ្យយើងម្នាក់ៗអាចធ្វើពិធីបរិសុទ្ធ និងសេចក្តីសញ្ញាដ៏នៅអស់កល្បជានិច្ចបាន ។ ពេលវេលាដ៏សេឡេស្ទាលបំផុតរបស់ខ្ញុំមួយចំនួននៅពេលថ្មីៗនេះគឺអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធរបស់កូនចៅរបស់ខ្ញុំផ្ទាល់ ដោយមានឪពុករបស់ខ្ញុំធ្វើពិធីបរិសុទ្ធពិសិដ្ឋនោះ ។

ខ្ញុំត្រេកអរនៅក្នុងកម្លាំងនៃយុវវ័យ នៅពេលខ្ញុំមើលឃើញពួកគេទៅព្រះវិហាបរិសុទ្ធ ដើម្បីធ្វើពិធីបុណ្យជ្រមុជទឹកសំរាប់មរណជន ។ ខ្ញុំស្រឡាញ់ភាពសក្តិសមរបស់ពួកគេ ក្នុងការប្រកាន់ខ្ជាប់នឹងបទដ្ឋានទាំងឡាយ ដែលនាំទៅកាន់ព្រះវិហារបរិសុទ្ធ និងការរៀបចំរបស់ពួកគេដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនាដ៏ស្មោះត្រង់ ហើយជាឪពុក និងម្តាយសុចរិត ។

ខ្ញុំត្រេកអរថាខ្ញុំជាបុត្រីម្នាក់របស់ព្រះវរបិតាសួគ៌ដែលស្រឡាញ់ខ្ញុំ ។ ខ្ញុំរៀនអំពីអត្តសញ្ញាណដ៏ទេវភាពរបស់ខ្ញុំ

នៅក្នុងជីវិតតាំងពីវ័យក្មេង ពីខាងម្តាយរបស់ខ្ញុំ។ ថ្មីៗនេះខ្ញុំបានឃើញចៅស្រីអាយុបីឆ្នាំរបស់ខ្ញុំ កំពុងតែរៀនអំពីអត្តសញ្ញាណរបស់នាងពីម្តាយរបស់នាង។ អេលីស្សា បានទៅចូលគេងទាំងមិនសប្បាយចិត្ត។ នាងអាចត្រូវបានលួងលោម តែនៅពេលណាម្តាយរបស់នាងប្រាប់រឿងពិតដែល អេលីស្សា ពេញចិត្តអំពីយប់ពិសេស នៅពេលព្រះវរបិតាសួគ៌បានខ្សឹបប្រាប់ដល់ដួងចិត្តរបស់ម្តាយនាងយ៉ាងច្បាស់ថា អេលីស្សា គឺជាវិញ្ញាណពិសេសមួយ ដែលមានបេសកកម្មដ៏ថ្លៃថ្លារៀបចំនៅពីខាងមុខ។

ខ្ញុំមានចិត្តត្រេកអរយ៉ាងខ្លាំងនៅក្នុងតួនាទីរបស់ខ្ញុំ ក្នុងនាមជាអ្នកចិញ្ចឹមបីបាច់ ដែលអនុញ្ញាតឱ្យខ្ញុំបង្ហាញនូវអត្តសញ្ញាណដ៏ជ្រាលជ្រៅបំផុតរបស់ខ្ញុំក្នុងនាមជាស្ត្រីម្នាក់។ ខ្ញុំតែងតែមានចិត្តស្ញប់ស្ញែង តាមរយៈរបៀបដែលស្ត្រីយុវនារី និងសូម្បីតែក្មេងស្រីតូច មាននូវចំណាប់អារម្មណ៍ពិសេស និងលទ្ធភាពនៅក្នុងការចិញ្ចឹមបីបាច់។ វាមិនមែនតែជាទំនួលខុសត្រូវចំបងរបស់ម្តាយប៉ុណ្ណោះទេ ប៉ុន្តែជាចំណែកនៃ "ជីវិតមុនផែនដី ជីវិតរមែងស្លាប់ និងអត្តសញ្ញាណ និងគោលបំណងរបស់បុគ្គលម្នាក់ៗ"។ ( "ក្រុមគ្រួសារ: ការប្រកាសដល់ពិភពលោក" *លីអាហូណា* ខែ តុលា ឆ្នាំ 2004, 49 )។ ដើម្បីចិញ្ចឹមបីបាច់ គឺត្រូវបង្រៀន អភិវឌ្ឍនូវការមើលថែ លើកទឹកចិត្តឱ្យមានការរីកចំរើន ផ្តល់អាហារ និងចិញ្ចឹមបីបាច់។ តើនរណាដែលមិនស្រែកដោយអំណរនៅពេលទទួលបានតួនាទីដែលបានប្រទានពរឱ្យមួយបែបនេះ?

បទគម្ពីរប្រើពាក្យចិញ្ចឹមបីបាច់តែពីរដងប៉ុណ្ណោះ ហើយនៅក្នុងករណីទាំងពីរនេះ និយាយអំពីទំនួលខុសត្រូវរបស់ឪពុកម្តាយ ដើម្បីចិញ្ចឹមកូនចៅរបស់ពួកគេនៅក្នុង "ដំបូន្មាន និងសេចក្តីដាស់តឿនរបស់ព្រះអម្ចាស់"។ (សូមមើល អេភេសូ 6:4 អេណុស 1:1)។ ប្រធាន ហ៊ិងគ្លី ក៏បានឱ្យដំបូន្មានផងដែរដល់ទាំងបុរស និងស្ត្រីឱ្យធ្វើជាអ្នកចិញ្ចឹមបីបាច់។ លោកបានមានប្រសាសន៍ថា:

"តើនឹងអស្ចារ្យជាងនេះយ៉ាងណាទៅ... បើសង្គមដែលយើងរស់នៅ មានឪពុក... ហើយម្តាយគ្រប់រូបមើលមកកូន [របស់ពួកគេ]... ជាអំណោយទានមកពីព្រះនៃស្ថានសួគ៌... ហើយបានថែរក្សាពួកគេដោយឥទ្ធិពលពិតនៅក្នុងគតិបណ្ឌិត និងដំបូន្មានរបស់ព្រះអម្ចាស់?" ("These, Our Little Ones," *លីអាហូណា* ខែ ធ្នូ ឆ្នាំ 2007, 7)។

ខ្ញុំត្រេកអរនៅក្នុងក្រុមគ្រួសារ។ ថ្មីៗនេះ ខ្ញុំបានត្រេកអរនៅក្នុងកំណើតចៅថ្មីម្នាក់មកក្នុងគ្រួសារមួយ ដែលយល់ថា ឪពុកម្តាយមានទំនួលខុសត្រូវដ៏ឧឡារិក ដើម្បីចិញ្ចឹមបីបាច់កូនចៅពួកគេដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត។ ពួកបងៗនាងមាននិស្ស័យធម្មជាតិចង់ដឹងចង់ឃើញ អំពីប្អូនស្រីតូចរបស់ខ្លួនចូលមកក្នុងពិភពលោកនេះ។ មេរៀនទីមួយរបស់ពួកគេអំពីប្រធានបទបរិសុទ្ធនេះ ត្រូវបានបង្រៀនដោយឪពុកម្តាយជាទីស្រឡាញ់ នៅក្នុងការបង្កើតគ្រួសារពិសិដ្ឋមួយ នៅក្នុងបរិដ្ឋានសេឡេស្ទាល ដែលនាំមកនូវកំនើតនៃវិញ្ញាណថ្មី ចូលមកក្នុងជីវិតរមែងស្លាប់ និងនៅក្នុងបរិបទនៃផែនការដ៏នៅអស់កល្បជានិច្ចដ៏មហិមា របស់ព្រះវរបិតារបស់យើង។ ផ្ទុយទៅវិញ នៅថ្ងៃបន្ទាប់ពេលត្រឡប់មកផ្ទះវិញ ពីសាលាមត្តេយ្យ ចៅស្រីរបស់យើងបានរាយការណ៍ថា នាងបានរៀននៅថ្ងៃនោះក្នុងថ្នាក់នូវ "ពាក្យធំថ្មីមួយ ដែលហៅថាការរំលោភបំពានខាងផ្លូវភេទ"។ ខ្ញុំមានអារម្មណ៍ព្រួយបារម្ភ ដែលកុមារបានដឹងអំពីរឿងនេះទៅហើយ ទាំងនៅក្មេងដើម្បីជាសុវត្ថិភាព ដើម្បីកែរឿងអវិជ្ជមាននៃប្រធានបទនេះ ពួកគេបាននិយាយគ្នាយ៉ាងល្អកាលពីយប់មុន។ ខ្ញុំមិនដែលត្រេកអរដូច្នេះទេពីមុនមកនៅក្នុងការចិញ្ចឹមបីបាច់ គ្រួសារបានស្ថាបនានៅលើការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ។

យ៉ាកុបបានបង្រៀនថា ព្រះអម្ចាស់សព្វព្រះហឫទ័យនឹង "ព្រហ្មចារីយភាពនៃស្ត្រី" (យ៉ាកុប 2:28)។ ខ្ញុំត្រេកអរនឹងព្រហ្មចារីភាព និងបរិសុទ្ធភាពរបស់បុរសស្ត្រីគ្រប់រូប។ តើវានឹងធ្វើឱ្យព្រះអម្ចាស់ព្រួយព្រះទ័យប៉ុណ្ណា ដែលទតឃើញថាគុណតម្លៃនេះត្រូវបានរំលោភបំពាន ហើយភាពរម្យទម្យត្រូវបានសើចចំអកនៅគ្រប់ទីកន្លែង ក្នុងពិភពលោកទុច្ចរិតនេះ។ ព្រះអម្ចាស់បានប្រទានដល់កូនចៅរបស់ទ្រង់នូវសេចក្តីអំណរដ៏មហិមា តាមរយៈភាពស្ថិតស្ថាល ទំនាក់ទំនងនៃក្តីស្រឡាញ់នៅពេលចៅៗរបស់ខ្ញុំបានរៀន។ ខ្ញុំត្រេកអរនៅក្នុងភាពច្បាស់លាស់នៃការប្រកាសដល់ពិភពលោក អំពីក្រុមគ្រួសារ ដែលបានព្រមានថា:

"បុគ្គលណាដែលរំលងលើសេចក្តីសញ្ញានៃព្រហ្មចារីភាព ដែលធ្វើបាបភរិយា ឬកូនចៅ ឬមិនបានបំពេញកិច្ចការនៃគ្រួសារគង់តែថ្ងៃណាមួយនឹងទទួលខុសត្រូវនៅចំពោះព្រះ"។

ខ្ញុំត្រេកអរនៅក្នុងគំរូនៃអ្នកទាំងឡាយនៅក្នុងបទគម្ពីរ អំពីអ្នកទាំងឡាយដែលដើរដោយសេចក្តីជំនឿ នៅក្នុងដំណើរនៅលើផែនដីរបស់ពួកគេ។ រាល់ពេល ខ្ញុំដើរជាមួយនឹងអ័ប្រាហាំ និងអ៊ីសាក នៅលើផ្លូវទៅកាន់ភ្នំម៉ូរ៉ា ខ្ញុំយំ ដោយដឹងថាអ័ប្រាហាំមិនដឹងថាមានទេវតាមួយអង្គ និងកូនចៀមមួយក្បាល នៅក្នុងព្រៃគម្ពោតនៅចុងបញ្ចប់នៃការធ្វើដំណើរទេ។ យើងម្នាក់ៗនៅកណ្តាលផ្លូវខាងផែនដីរបស់យើង ហើយយើងមិនដឹងថារឿងដែលនៅសល់ក្នុងជីវិតរបស់យើងផ្ទាល់មានអ្វីខ្លះទៀតទេ។ ប៉ុន្តែយើងដូចជាអ័ប្រាហាំ យើងត្រូវបានប្រទានពរដោយអព្ភូតហេតុជាច្រើន។

ខ្ញុំត្រេកអរនៅក្នុង "ព្រះគុណ និងអព្ភូតហេតុទាំងឡាយ" របស់ព្រះអម្ចាស់ (សូមមើល "Bless Our Fast, We Pray," *ទំនុកដំកើង* លេខ 138)។ យើងដឹងថាព្រះគុណដ៏ទន់ភ្លន់របស់ទ្រង់ និងអព្ភូតហេតុរបស់ទ្រង់ ទាំងតូចទាំងធំគឺជាការពិត។ ព្រះគុណ និងអព្ភូតហេតុទាំងនោះមកតាមរបៀបរបស់ទ្រង់ និងពេលវេលារបស់ទ្រង់។ នៅពេលខ្លះវាមិនមានមកទេ រហូតដល់យើងបានឈានទៅដល់កំរិតរបស់យើង។ ពួកសិស្សរបស់ព្រះយេស៊ូវនៅសមុទ្រកាលីឡេ ត្រូវតែខំយ៉ាងខ្លាំងដើម្បីបើកទូកប្រយុទ្ធនឹងខ្យល់ ពេញមួយយប់មុនពេលព្រះយេស៊ូវយាងមកជួយពួកគេនៅទីបញ្ចប់។ ទ្រង់មិនបានយាងមករហូតដល់ "យាមបួនយប់" មានន័យថាជិតរះ។ ពេលនោះទ្រង់បានយាងមក។ (សូមមើលម៉ាកុស 6:45--51)។ ទីបន្ទាល់របស់ខ្ញុំគឺថាអព្ភូតហេតុទាំងឡាយពិតជាកើតមាន ទោះបីជាពេលខ្លះមិនកើតមាន រហូតដល់យាមបួនយប់ក៏ដោយ។

ឥឡូវនេះ ខ្ញុំដាក់សេចក្តីជំនឿ និងការអធិស្ឋានរបស់ខ្ញុំ និងការទន្ទឹងមើលអព្ភូតហេតុជំនួសឱ្យមនុស្សជាទីស្រឡាញ់ ដែលមានជំងឺខាងរាងកាយ មានការនឿយហត់ខាងសតិអារម្មណ៍ និងដែលវង្វេងខាងវិញ្ញាណ។ ខ្ញុំត្រេកអរនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ ចំពោះកូនចៅរបស់ទ្រង់ម្នាក់ៗ និងនៅក្នុងប្រាជ្ញារបស់ទ្រង់ ដើម្បីអនុញ្ញាតឱ្យយើងម្នាក់ៗសម្របនឹងបទពិសោធន៍ខាងលោកិយ។

នៅទីបញ្ចប់ ខ្ញុំត្រេកអរហួសពីខ្ញុំអាចរៀបរាប់បានចំពោះ សេចក្តីស្រឡាញ់ដ៏នៅអស់កល្បជានិច្ច និងការជួយយ៉ាងខ្ជាប់ខ្ជួនរបស់ស្វាមីខ្ញុំ និងការអធិស្ឋាន ហើយការគាំទ្រពីកូនៗរបស់ខ្ញុំ និងឪពុកម្តាយ អំឡុងពេលប៉ុន្មានឆ្នាំនេះនៃការបំរើរបស់ខ្ញុំ ក្នុងនាមជាប្រធានយុវនារីទូទៅ។

"ព្រលឹងខ្ញុំត្រេកអរចំពោះការណ៍ទាំងឡាយនៃព្រះអម្ចាស់" (នីហ្វៃទី 2 4:16)--- ក្រិត្យវិន័យរបស់ទ្រង់ជីវិតរបស់ទ្រង់ សេចក្តីស្រឡាញ់របស់ទ្រង់។ ដើម្បីត្រេកអរនៅក្នុងទ្រង់ គឺត្រូវស្គាល់ព្រះហស្តរបស់ទ្រង់ដាក់នៅក្នុងជីវិត

របស់យើង។ កិច្ចការរបស់យើងក្នុងដំណឹងល្អ គឺដើម្បីធ្វើអ្វីដែលត្រឹមត្រូវ ដើម្បីស្រឡាញ់ និងត្រេកអរនៅក្នុងអ្វីដែលត្រូវ។ នៅពេលយើងត្រេកអរបំរើដល់ទ្រង់ នោះព្រះវរបិតាសួគ៌របស់យើងសព្វព្រះហឫទ័យនឹងប្រទានពរដល់យើង។ "យើងជាព្រះអម្ចាស់... សព្វព្រះហឫទ័យនឹងផ្តល់ឱ្យកិត្តិយសដល់អស់អ្នកណា ដែលបំរើយើងដោយនូវសេចក្តីសុចរិត និងដោយនូវសេចក្តីពិតរហូតដល់ចុងបំផុត" (គ. និង ស. 76:5)។ ខ្ញុំចង់មានភាពសក្តិសមនៃការសព្វព្រះហឫទ័យរបស់ទ្រង់ជានិច្ច។ "ខ្ញុំស្រឡាញ់ព្រះអម្ចាស់ នៅក្នុងទ្រង់ព្រលឹងរបស់ខ្ញុំត្រេកអរ" ("I Love the Lord," Jackman Music Corporation)។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។